**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៣.សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង រៀបចំមហោស្រពសិល្បៈចម្រៀងខ្មែរជាសកល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ សម្រាប់រៀបចំមហោស្រពសិល្បៈចម្រៀងខ្មែរជាសកល ដោយបើកទូលាយឱ្យបេក្ខជនចូលរួមពីគ្រប់មជ្ឈដ្ឋាន រួមទាំងអនិកជនខ្មែររស់នៅឯបរទេសផង ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ហ៊ឹម ឆែម** | រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ប្រធាន |
| ២- ឯកឧត្តម | **ពុខ ឃាងសែ** | ទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | អនុប្រធាន |

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ៣- ឯកឧត្តម | ឃឹម សារិទ្ធ | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- លោកជំទាវ | ម៉ិញ កុសនី | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៥- ឯកឧត្តម | អ៊ុក សុជាតិ | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធានអចិន្ត្រៃយ៍ |
| ៦- ឯកឧត្តម | ទេព នន្ទរី | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- ឯកឧត្តម | ជា ម៉េងឈាង | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- ឯកឧត្តម | ជ័យ ចាប | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩- ឯកឧត្តម | សោម សុគន្ធ | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១០- ឯកឧត្តម | ម៉េង ឃួរ | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១១- ឯកឧត្តម | សំរ៉េង កំសាន្ត | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១២- ឯកឧត្តម | ឃាំ សុខុម | អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ១៣- ឯកឧត្តម | ស្ងួន ឈាងលី | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៤- ឯកឧត្តម | ចាន់ គីស៊ីម | ទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៥- ឯកឧត្តម | មាស សារុន | អគ្គនាយកបច្ចេកទេសវប្បធម៌ | សមាជិករាយការណ៍ |
| ១៦- លោក | ធិត ដារ៉ារិទ្ធ | អគ្គនាយករងទទួលបន្ទុកការងារប្រតិបត្តិ នៃអគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន | សមាជិក |
| ១៧- លោក | ចំរួន សំអាន | អភិបាលរងរាជធានីភ្នំពេញ | សមាជិក |

**ប្រការ ២.-**

គណៈកម្មការនេះ មានភារកិច្ចរៀបចំ និងគ្រប់គ្រងដំណើរការមហោស្រពសិល្បៈចម្រៀងខ្មែរជាសកល ដែលនឹងប្រព្រឹត្តទៅក្នុងខែ កក្កដា ឆ្នាំ ២០១០ ឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ ៣.-**

គណៈកម្មការនេះ ត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅទីស្តីការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីចាត់ចែងការងារប្រចាំថ្ងៃ និងត្រូវបានបង្កើតអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់។

**ប្រការ ៤.-**

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សម្រាប់សម្រួលការងារ។

**ប្រការ ៥.-**

សមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

www.pheakdeylaw.com

**ប្រការ ៦.-**

ថវិកាចំណាយសម្រាប់ដំណើរការមហោស្រពសិល្បៈ បានមកពីចំណូលរបស់សប្បុរសជន និងការរួមចំណែកថវិកាបដិភាគរបស់រដ្ឋ ។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អភិបាលរាជធានីភ្នំពេញ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ៥ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ធនាគារកាណាឌីយ៉ា*
- *អគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន*
- *ដូចប្រការ ៨*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com